# សេចក្តីប្រកាស
# មូលនិធិដាំដុះ សម្រាប់គម្រោង ឆ្នាំ២០២៦
# «កម្មវិធីមូលនិធិ»

សិល្បៈខ្មែរអមតៈ

**ព័ត៌មានសំខាន់ៗ**

| | |
|---|---|
| ឱកាស | មូលនិធិ «ដាំដុះ» សម្រាប់គម្រោង ឆ្នាំ២០២៦ |
| រចនាឡើងដើម្បី | ជួយគាំទ្រដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ |
| អ្នកចូលរួមសរុប | ចំនួន ៤ កន្លែង |
| គម្រោង & ពេល | គម្រោងនៅចន្លោះខែ កុម្ភៈ ដល់ខែ ធ្នូ ឆ្នាំ២០២៦ |
| កាលបរិច្ឆេទសំខាន់ៗ | ១. វេទិកាសំណួរចម្លើយនៅអង្គការសិល្បៈខ្មែរអមតៈ ដោយផ្ទាល់ និង រឺតាមរយៈ Zoom នៅថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ ២០២៦ វេលាម៉ោង ៦:០០ ដល់ម៉ោង ៧:៣០<br>២. កាលបរិច្ឆេទសម្ភាសនៅចន្លោះថ្ងៃទី៤  ដល់ ៦ ខែមីនា ឆ្នាំ២០២៦<br>៣. កាលបរិច្ឆេទផ្តល់ដំណឹងអំពីលទ្ធផលនៅចន្លោះថ្ងៃទី ១០ ដល់ ១២ ខែ មីនា ឆ្នាំ២០២៦ |
| ទំហំមូលនិធិ | រហូតដល់ ២៥០០ ដុល្លារអាមេរិក |
| ផុតកំណត់ទទួលពាក្យ | «ថ្ងៃទី២៨  ខែ កុម្ភៈ ឆ្នាំ២០២៦» |

អង្គការសិល្បៈខ្មែរអមតៈមានសេចក្តីរីករាយ នឹងប្រកាសបើកមូលនិធិ «ដាំដុះ» សរុប «៤» កន្លែង ដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ ដើម្បីយកទៅអនុវត្តគម្រោងរបស់ខ្លួន។
មូលនេះត្រូវបានបង្កើតឡើងដើម្បីគាំទ្រសិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ សម្រាប់គាំទ្រអ្នកដែលទើបចាប់ផ្តើមការងារក្នុងគំនិតផ្តួចផ្តើម ឬពិសោធន៍គម្រោងរបស់ខ្លួន។

ពួកគាត់អាចស្នើសុំមូលនិធិនេះដើម្បីគាំទ្រគម្រោងទាំងមូល ឬដំណាក់កាលណាមួយនៃគម្រោងរបស់ខ្លួន។ គម្រោងទាំងនោះដូចជា៖ អភិវឌ្ឍគម្រោងច្នៃប្រឌិតថ្មីៗ គម្រោងសិល្បៈសហគមន៍ គម្រោងស្រាវជ្រាវ គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា។

គោលបំណងរយៈពេលវែងនៃ មូលនិធិ គឺផ្តោតសំខាន់ជាពិសេសទៅលើគំនិតច្នៃប្រឌិត  ភាពជាអ្នកដឹកនាំ និងការបង្ហាញគម្រោងច្នៃប្រតិដ្ឋទាំងនេះទៅកាន់ទស្សនិកជន។ មូលនិធិនេះបើកទូលាយចំពោះគ្រប់ទម្រង់សិល្បៈ លើកលែងតែការដំឡើងស្នាដៃសិល្បៈទស្សនីយភាព។

គម្រោងទាំងអស់ត្រូវកើតឡើងក្នុងឆ្នាំ ២០២៦ ចាប់ពី «ខែ កុម្ភៈ ដល់ ខែធ្នូ ឆ្នាំ២០២៦»។ កម្មវិធីនេះសម្របសម្រួល កញ្ញា សាយ តុលា អ៊ីមែល tola@cambodianlivingarts.org រឺលេខទូរសព្ទ ០៧៧ ៥៥ ៨៥ ៤៥។

**ព័ត៌មានលម្អិតបន្ថែមស្តីពី ៖**

១. គោលដៅមូលនិធិ

មូលនិធិ «ដាំដុះ» សម្រាប់គម្រោងបង្កើតឡើងដើម្បីគាំទ្រដល់៖

- គម្រោងថ្មី/គម្រោងសិល្បៈច្នៃប្រតិដ្ឋ លើកលែង រឺមិនរាប់បញ្ចូលគម្រោងសិល្បៈទស្សនីយភាព
- គម្រោងសិល្បៈសហគមន៍
- គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា

២. អត្ថប្រយោជន៍របស់មូលនិធិ

ទទួលបានប្រាក់ឧបត្ថម្ភ ឬ ប្រាក់រង្វាន់រហូតដល់ ២៥០០ ដុល្លារអាមេរិក។

(សម្គាល់៖ មូលនិធិភាគច្រើនទទួលបានប្រាក់ឧបត្ថម្ភពីចន្លោះ ២០០០ - ២៥០០ ដុល្លារអាមេរិក)

៣. អ្នកចូលរួមគោលដៅរបស់មូលនិធិ

- សិល្បករ និងអ្នកជំនាញផ្នែកសិល្បៈ និងវប្បធម៌
- អ្នកស្រាវជ្រាវ និស្សិត អ្នកនិពន្ធ និង អ្នកធ្វើវិវេចនា
- សមាជិកក្នុងសហគមន៍

**លក្ខខណ្ឌជ្រើសរើស៖**

ត្រូវតែបំពេញនៅលើទម្រង់ស្នើសុំរបស់អង្គការសិល្បៈខ្មែរអមតៈ។ សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដែលយើងតម្រូវឱ្យមានឱ្យបានត្រឹមត្រូវ។ លោកអ្នកអាចបំពេញពាក្យស្នើសុំជាភាសាខ្មែរ ឬអង់គ្លេស ឬថតចម្លើយជាវីដេអូ រឺសំឡេងក៏បាន។

1. ពាក្យស្នើសុំអាចបំពេញដោយដៃ ឬដោយកុំព្យូទ័រ។ *(ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០៧៧ ៥៥ ៨៥ ៥៥ ។)*
2. អាចធ្វើឡើងដោយបុគ្គលម្នាក់ ឬជាក្រុម។ ក្នុងករណីជាក្រុម ត្រូវបញ្ជាក់ឈ្មោះតែប្រធានក្រុម ឬអ្នកតំណាងក្រុម។
3. ត្រូវបង្ហាញពី:
    - ការប្តេជ្ញាចិត្តក្នុងការអនុវត្តគម្រោងរបស់ខ្លួន
    - ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន, ប្រវត្តិនៃការអប់រំ និងការងារក្នុងវិស័យសិល្បៈ និងវប្បធម៌
    - ចក្ខុវិស័យនៃគម្រោងរបស់ខ្លួន ថាតើវានឹងជួយដល់ការអភិវឌ្ឍវិស័យសិល្បៈវប្បធម៌ដោយរបៀបណា។
4. មូលនិធិនេះ សម្រាប់អ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa។[1]

[1] បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ មិនអាចដាក់ពាក្យស្នើសុំមូលនិធិនេះទេ។

សិល្បៈខ្មែរអមតៈ ប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីអាយុ ពិការភាព ជនជាតិដើមភាគតិច ភេទ អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា និងសង្គមសេដ្ឋកិច្ចឡើយ។

*យើងសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ ដែលមានសំឡេងតិច ហើយយើងនឹងផ្តល់ការគាំទ្រ (អាស្រ័យលើតម្រូវការ និងភាពចាំបាច់) ទៅដល់បេក្ខជនដែលទទួលបានជោគជ័យ។* ពួកយើងផ្តល់អាទិភាពដល់អ្នកដែលមិនធ្លាប់ទទួលបានឱកាសបែបនេះពីមុនមក។

៥. គម្រោងនិងពេលរបស់មូលនិធិ
   - គម្រោងត្រូវអនុវត្តគម្រោងនៅចន្លោះខែកុម្ភៈ ដល់ខែធ្នូ ឆ្នាំ២០២៦
៦. ក្រុមពាក់ព័ន្ធនឹងមូលនិធិ
   ១. កញ្ញា យ៉ុន សុខខន នាយិកាគ្រប់គ្រងកម្មវិធី
   ២. កញ្ញា សាយ តុលា អ្នកសម្របសម្រួលកម្មវិធីមូលនិធិ

៧. ការសង្ខេបឡើងវិញអំពីកាលបរិច្ឆេទសំខាន់ៗ
   ១. វេទិកាសំណួរចម្លើយនៅអង្គការសិល្បៈខ្មែរអមតៈ ដោយផ្ទាល់ និង រឺតាមរយៈ Zoom នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២៦ វេលាម៉ោង៦:០០ ដល់ម៉ោង ៧:៣០
   ២. កាលបរិច្ឆេទសម្ភាស នៅចន្លោះថ្ងៃទី ០៤ ដល់ ០៦ ខែមីនា ឆ្នាំ២០២៦
   ៣. កាលបរិច្ឆេទផ្តល់ដំណឹង នៅចន្លោះថ្ងៃទី ១០ ដល់១២ ខែមីនា ឆ្នាំ២០២៦

## លក្ខណសម្បត្តិត្រូវការ

ដើម្បីអាចចូលរួមកម្មវិធីបាន បេក្ខជនត្រូវ៖ សរសេរលក្ខណសម្បត្តិដែលត្រូវនឹងលក្ខខណ្ឌទាំងអស់នៅទីនេះ

- ត្រូវមានញាតិខ្មែរ / កំពុងស្នាក់នៅប្រទេសកម្ពុជាកំឡុងពេលអនុវត្តគម្រោង
- មានពេលគ្រប់គ្រាន់សម្រាប់ចូលរួមកម្មវិធីតាមកាលបរិច្ឆេទទាំងអស់ដែលបានកំណត់ខាងលើ
- មានឆន្ទៈក្នុងការចូលរួមសហការ និងការតាំងចិត្តខ្ពស់ក្នុងការដឹកនាំ និងអនុវត្តគម្រោងមូលនិធិ ។
- មានការប្តេជ្ញាចិត្តក្នុងការសហការជាមួយអង្គការសិល្បៈខ្មែរអមតៈ ដើម្បីធ្វើបទបទបង្ហាញចែករំលែកអំពីគម្រោងរបស់ខ្លួននៅរាជធានីភ្នំពេញ  នៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២៦

## របៀបដាក់ពាក្យ៖

សូមបំពេញព័ត៌មានរបស់អ្នក និងឆ្លើយសំណួរនៅក្នុងពាក្យស្នើសុំដែលភ្ជាប់មកជាមួយនឹងសេចក្តីប្រកាសនេះ។ អ្នកអាចផ្ញើពាក្យស្នើសុំរបស់អ្នកទៅកាន់អ៊ីមែល tola@cambodianlivingarts.org រឺតាមរយៈតេឡេក្រាមលេខ ០៧៧ ៥៥ ៨៥ ៤៥ ត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង ១១:៥៩ យប់។

**វគ្គសំណួរនិងចម្លើយ**

ពួកយើងនឹងបើកវេទិកាសំណួរចម្លើយតាមអនឡាញ និងជួបផ្ទាល់ដែលលោកអ្នកនឹងមានឱកាសជួបជាមួយនឹង «ក្រុមការងារអង្គការសិល្បៈអមតៈ» ដើម្បីពិភាក្សាជុំវិញមូលនិធិ និងដំណើរការ នៃការដាក់ពាក្យ។
កាលបរិច្ឆេទ៖ «ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៦» ម៉ោង: «០៦:០០ ល្ងាច ដល់ម៉ោង ៧:៣០ យប់»
រឺចូលរួមតាមតំណភ្ជាប់ខាងក្រោម៖
« https://us02web.zoom.us/j/8127047219?omn=88157729265» Meeting ID: 812 704 7219